ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខៈ ០៨៤.................. សហអ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

<u>តាមរយៈ:</u> ឯកឧត្តម អគ្គនាយក ទទួលបន្ទុក
<u>កម្មវត្ថុ:</u> របាយការណ៍ស្តីពីបេសកកម្មត្រួតពិនិត្យគម្រោង EIF របស់ UNOPS និង EIF ES
<u>យោង:</u> Email របស់ UNOPS ចុះថ្ងៃទី ២៣ មេសា ២០១៥ របស់ UNOPS
<u>ជូនភ្ជាប់:</u> (1) ToR, (2) Agenda, (3) Presentation

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរព និង រាយការណ៍ជូន ឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា: រៀងរាល់ ៦ ខែម្តង UNOPS នឹងបញ្ជូនបេសកកម្មរបស់ខ្លួនដើម្បីត្រួតពិនិត្យ, តាមដាន, និងគាំទ្រដល់ការអនុវត្តកម្មវិធីពង្រឹងសមាហរណកម្ម (EIF) នៅក្នុងប្រទេសកម្ពុជា។ បេសកកម្មលើកនេះជាបេសកកម្មរួមគ្នារវាង UNOPS ដែលជា Trust Fund Manager ដឹកនាំដោយលោក **Ratnasabapathy Manivannan |** Regional Portfolio Manager –EIF TFM និង EIF Executive Secretariat ដឹកនាំដោយលោកស្រី Hang TRAN | Coordinator ចាប់ពីថ្ងៃទី ០៤ ដល់ ០៨ ឧសភា ឆ្នាំ ២០១៥ ។ គោលបំណងសំខាន់នៃបេសកកម្មត្រួតពិនិត្យរួមគ្នានេះ មានដូចខាងក្រោម៖

(១) សម្រាប់អ្នកសម្របសម្រួលប្រតិបត្តិលេខាធិការដ្ឋានរបស់ EIF
- ពិនិត្យមើលសមិទ្ធផលដែលសម្រេចបានក្រោមកម្មវិធី EIF Tier 1, កម្មវិធី CEDEP I និង CEDEP II,
- វឌ្ឍនភាពនៃការរៀបចំផែនការរយៈពេលមធ្យម (MTP) និងសូចនាករពាណិជ្ជកម្ម,
- ការរៀបចំនិងការអនុវត្តន៍យុទ្ធសាស្ត្រនិរន្តរភាពរបស់កម្មវិធី EIF Tier 1, និង
- ការកៀងគរធនធាន និងការអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (CTIS 2014-2018) និងផែនទីបង្ហាញផ្លូវ (Trade SWAp Roadmaps)។

(២) សម្រាប់ប្រធានគ្រប់គ្រងហិរញ្ញវត្ថុប្រចាំតំបន់របស់អង្គការ UNOPS ៖
- សម្របសម្រួលការអនុវត្តន៍កម្មវិធី EIF Tier 1, កម្មវិធី CEDEP I និង CEDEP II ឲ្យអនុលោមទៅតាមលក្ខខណ្ឌគ្រប់គ្រងហិរញ្ញវត្ថុ និងអនុសាសន៍នានាដែលលើកឡើងដោយ

ក្រុមប្រឹក្សាភិបាលរបស់ EIF (EIF Board), ប្រតិបត្តិលេខាធិការដ្ឋានរបស់ EIF (EIF ES), និង ប្រធានគ្រប់គ្រងហិរញ្ញវត្ថុប្រចាំតំបន់ (TFM),

- លើកកម្ពស់វឌ្ឍនភាពការងារ, និង (គ) ដោះស្រាយបញ្ហានានាដែលអាចកើតមានឡើងចំពោះការគ្រប់គ្រង និងប្រតិបត្តិការហិរញ្ញវត្ថុរបស់គម្រោង។

ខ្ញុំបាទសូមដកស្រង់នូវចំណុចសំខាន់ៗ នៃបេសកកម្មត្រួតពិនិត្យរួមគ្នានេះមានដូចខាងក្រោម ៖

១). EIF Tier 1:

ក. ផ្នែកហិរញ្ញវត្ថុ:

- ចំណាយសរុបគិតមកដល់ដំណាច់ខែ មីនា ២០១៥ មានចំនួន $1,027,945 ឬ 79% នៃថវិកាសរុបរបស់កម្មវិធី EIF Tier 1 (ចំនួន $1,293,900), ថវិកានៅសល់មានចំនួន $ 265,955 ។ គម្រោង EIF Tier 1 នឹងត្រូវបញ្ចប់នៅខែ កក្កដា ២០១៥ ខាងមុខនេះ ប៉ុន្តែដោយសារថវិកានៅសល់ និងមានសកម្មភាពសំខាន់ៗមួយចំនួនពុំទាន់បានអនុវត្ត DICO បានស្នើសុំពន្យាការអនុវត្តកម្មវិធី EIF Tier 1 ដោយមិនមានការប្រែប្រួលទៅលើថវិកា (No-Cost Extension) រយៈពេល ៨ខែ រហូតដល់ខែ មីនា ឆ្នាំ ២០១៦។
- ចំពោះការចំណាយនៅក្នុងត្រីមាសទី១ ឆ្នាំ២០១៥ គឺមានចំនួន $37,517 ។

ខ. ផ្នែកលទ្ធកម្ម:

- ការបន្តកិច្ចសន្យាឲ្យទីប្រឹក្សាអន្តរជាតិសម្រាប់ជំនួយពាណិជ្ជកម្ម
- ការបន្តកិច្ចសន្យាឲ្យទីប្រឹក្សាជាតិសម្រាប់ការងារទំនាក់ទំនង
- ការបន្តកិច្ចសន្យាឲ្យជំនួយការរដ្ឋបាលនិងលទ្ធកម្ម
- ចុះកិច្ចសន្យាការងារជាមួយប្រធានកម្មវិធីពង្រឹងសមាហរណកម្ម
- បានជ្រើសរើសទីប្រឹក្សាជាតិនិងអន្តរជាតិសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិនៃគម្រោង EIF Tier 2 - CEDEP I

គ. សកម្មភាពការងារផ្សេងៗដែលយើងបានអនុវត្តកន្លងមក:

- បន្តបញ្ជូនមន្ត្រីចំនួន ១៣ រូប មកពីក្រសួងពាក់ព័ន្ធចូលរួមវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅមជ្ឈមណ្ឌលអូស្ត្រាលី ភ្នំពេញ (សម្រាប់ត្រីមាសទី១ និងត្រីមាសទី២ ឆ្នាំ ២០១៥)។
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៤ និងបានផ្ញើជូន EIF ES and EIF TFM ។
- រៀបចំបោះពុម្ពផ្សាយព្រឹត្តិបត្តិព័ត៌មានប្រចាំឆមាសរបស់ Trade SWAp។
- ធ្វើបច្ចុប្បន្នភាពផែនការការងារ និងផែនការថវិកា សម្រាប់ការស្នើសុំពន្យាការអនុវត្តកម្មវិធី EIF Tier 1 ដោយគ្មានថវិកាបន្ថែម (No-Cost Extension) រយៈពេល ៨ខែ រហូតដល់ខែ មីនា ឆ្នាំ ២០១៦ និងបានផ្ញើជូន EIF TFM UNOPS ដើម្បីពិនិត្យ និងធ្វើការអនុម័ត ។
- ធ្វើបច្ចុប្បន្នភាពផែនការការងារនិងផែនការថវិកាសម្រាប់ការងារទំនាក់ទំនងនិងផ្សព្វផ្សាយ។
- បន្តគាំទ្រដល់ការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអនុវត្តន៍គម្រោង (IC) ប្រចាំខែ។
- បន្តគាំទ្រដល់ការរៀបចំកិច្ចប្រជុំអនុគណៈកម្មាធិការដឹកនាំ (S-SC) ប្រចាំត្រីមាស។
- ធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍លើកទី៤ នៅក្នុងប្រទេសឡាវពីថ្ងៃទី៣-៥ ធ្នូ ២០១៤ ។

- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី១ នៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០១៥ ដើម្បីចែករំលែកព័ត៌មានអនុវត្តគម្រោងក្រោមកម្មវិធី EIF Tier 1 និង CEDEP I និង CEDEP II។
- រៀបចំទទួលដំណើរទស្សនកិច្ចសិក្សាពីនាយកដ្ឋានសិក្សាអន្តរជាតិ នៃសាកលវិទ្យាល័យកូរ៉េខាងត្បូង ដើម្បីស្វែងយល់ពីជំនួយសម្រាប់ពាណិជ្ជកម្ម, អភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម, អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជ, គម្រោង TDSP, និង កម្មវិធី EIF នៅកម្ពុជា កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ ២០១៥។
- រៀបចំទទួលបេសកកម្មសិក្សារបស់បុគ្គលិកកម្មវិធី EIF នៃប្រទេស វ៉ានូអាទូ ដើម្បីស្វែងយល់ពីជំនួយសម្រាប់ពាណិជ្ជកម្ម និង ការអនុវត្តកម្មវិធី EIF នៅកម្ពុជា កាលពីថ្ងៃទី២១-២២ ខែមករា ឆ្នាំ ២០១៥។
- រៀបចំទទួលបេសកកម្មសិក្សារបស់លោក Peter Cederblad, មន្ត្រីរបស់ SIDA ប្រចាំនៅទីក្រុង Stockholm ដើម្បីស្វែងយល់ពីការអនុវត្តកម្មវិធី EIF នៅកម្ពុជា កាលពីថ្ងៃទី១០-១១ ខែមីនា ឆ្នាំ ២០១៥។
- គាំទ្រការអញ្ជើញចូលរួមរបស់មន្ត្រីបង្គោល EIF (EIF Focal Point), នាយកអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIU Director), និងទីប្រឹក្សាអន្តរជាតិសម្រាប់ជំនួយពាណិជ្ជកម្ម នៅក្នុងវេទិកាសកលរបស់កម្មវិធី EIF ចាប់ពីថ្ងៃទី១៧-១៩ ខែមីនា ឆ្នាំ ២០១៥ នៅទីក្រុងហ្សឺណែវ។
- ធ្វើការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយអង្គការ UNDP ដើម្បីរៀបចំផែនការរយៈពេលមធ្យម ២០១៦-២០២០ MTP (Medium-Term Plan 2016-2020) ហើយបេសកកម្មលើកទី១ បានចាប់ផ្តើមពីថ្ងៃទី ៣១ ខែ មីនា ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥។

២). EIF Tier 2:

ក. CEDEP I:

- <u>សមាសភាគសូត្រប្រណិត (High Value Silk Component) អនុវត្តគម្រោងដោយ ITC:</u>

- នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្មបានធ្វើការជាមួយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) និងភាគីពាក់ព័ន្ធដទៃទៀត ជម្រុញឲ្យមានការបង្កើតក្រុមប្រឹក្សាភិបាលសូត្រជាតិតាមរយៈប្រកាស និងប្តូរឈ្មោះពីក្រុមប្រឹក្សាភិបាលសូត្រជាតិទៅជា **គណៈកម្មការជំរុញ និងអភិវឌ្ឍន៍វិស័យសូត្រកម្ពុជា** ជំនួសវិញ ។ ប្រកាសស្តីពីការបង្កើតគណៈកម្មការជំរុញ និងអភិវឌ្ឍន៍វិស័យ សូត្រកម្ពុជា ត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី២០ ខែ មីនា ឆ្នាំ២០១៥។
- សមាសភាគសូត្រប្រណិតដែលអនុវត្តដោយ ITC គ្រោងនឹងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១៥ ប៉ុន្តែដោយសារលទ្ធផលរំពឹងទី៣ (Outcome 3) របស់គម្រោងមិនទាន់សម្រេចបានជោគជ័យ ITC បានស្នើសុំពន្យាការអនុវត្តសមាសភាគសូត្រប្រណិតក្នុងរយៈពេល ៦ខែ ដោយមិនមានការប្រែប្រួលទៅលើថវិកា (No-Cost Extension) រយៈពេល ៦ខែ រហូតដល់ខែ មិនា ឆ្នាំ ២០១៦។

- ITC បានបន្តកម្មវិធីកសាងសមត្ថភាពឲ្យដល់អ្នកទទួលផលដោយផ្ទាល់របស់គម្រោង (Beneficiary) តាមរយៈវគ្គបណ្តុះបណ្តាលជំនាញបច្ចេស និងដំណើរទស្សនកិច្ចសិក្សា និងតាំងពិព័រណ៍ពាណិជ្ជកម្មនៅក្រៅប្រទេស។
- អ្នកទទួលផលដោយផ្ទាល់ពីគម្រោងសមាសភាគសូត្រប្រណិតបានសំដែងពីភាពជោគជ័យ នៅក្នុងអាជីវកម្មរបស់ខ្លួននិងលទ្ធផលជាវិជ្ជមាន ដែលទទួលបានពីគម្រោងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបានស្នើសុំដល់កម្មវិធីពង្រឹងសមាហរណកម្ម EIF និងក្រសួងពាណិជ្ជកម្មឲ្យបន្តផ្តល់ជំនួយបច្ចេកទេសដល់ពួកគេជាបន្តទៀត ។

➤ <u>សមាសភាគអង្ករ (Milled Rice Component) អនុវត្តគម្រោងដោយ IFC:</u>

- សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) ត្រូវបានបង្កើតឡើងជាផ្លូវការនៅ ខែឧសភា ឆ្នាំ ២០១៤ ដោយមានសមាជិកក្រុមប្រឹក្សាប្រតិបត្តិចំនួន ១៥ ដែលបានជាប់ឆ្នោតក្នុងនោះមានទាំងប្រធាន និងអនុប្រធានសហព័ន្ធអង្ករកម្ពុជា។
- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ CRF ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រដាក់ស្លាកសញ្ញានៅលើអង្ករក្រអូបកម្ពុជា។ យុទ្ធសាស្ត្រនេះត្រូវបានគាំទ្រដោយ CRF និងក្រុមហ៊ុននាំចេញសំខាន់ៗមួយចំនួន។ បច្ចុប្បន្ននេះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) កំពុងធ្វើការជាមួយ CRF ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ។
- មានរោងម៉ាស៊ីនកិនស្រូវចំនួនប្រាំពីរបានទទួលវិញ្ញាបនបត្រការវិភាគគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (HACCP) ។
- ប្រមាណ ៩២% នៃរោងម៉ាស៊ីនកិនស្រូវ បានរាយការណ៍ថា ពួកគាត់មានលទ្ធភាពចូលទៅកាន់ទីផ្សារអន្តរជាតិកាន់តែល្អប្រសើរឡើង ហើយ ៨៣% បានរាយការណ៍ថាផលិតភាព និងការអនុវត្តន៍ការងារត្រូវបានលើកកម្ពស់ ដែលជាលទ្ធផលនៃការអនុវត្តន៍ វិញ្ញាបនបត្រ HACCP ។
- សមាសភាគអង្ករដែលអនុវត្តដោយ IFC គ្រោងនឹងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ប៉ុន្តែដោយសារមានសកម្មភាពមួយចំនួនមិនទាន់បានបញ្ចប់ IFC បានស្នើសុំពន្យាការអនុវត្តសមាសភាគអង្ករក្នុងរយៈពេល ៦ខែ ដោយមិនមានការប្រែប្រួលទៅលើថវិកា (No-Cost Extension) រហូតដល់ខែ មិថុនា ឆ្នាំ ២០១៦។

៤. CEDEP II:

➤ <u>សមាសភាគដំឡូងមី (Cassava Component) អនុវត្តគម្រោងដោយអង្គការ UNDP:</u>

- រៀបចំបង្កើតយុទ្ធសាស្ត្រអនុវត្តគម្រោង
- ធ្វើបច្ចុប្បន្នភាពផែនការអនុវត្តគម្រោងឆ្នាំ ២០១៥
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលគម្រោង
- កំណត់អត្តសញ្ញាណនៃភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យដំឡូងមី ។

- ចុះបេសកកម្មទៅកាន់តំបន់គោលដៅរបស់គម្រោង ដើម្បីសិក្សាស្វែងយល់ពីស្ថានភាពទូទៅរបស់អ្នកទទួលផល និងភាគីពាក់ព័ន្ធសំខាន់ៗរបស់គម្រោង ។
- ធ្វើការសិក្សាពីខ្សែចង្វាក់តម្លៃរបស់ដំឡូងមី ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម ក្នុងការបង្កើតសមាគមដំឡូងមីនៅក្នុងតំបន់គោលដៅរបស់គម្រោង ។
- រៀបចំកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលសម្រាប់សមាជិកក្រុមស្នូល (Core Team Members) របស់គម្រោង ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នៃក្រសួងពាណិជ្ជកម្ម ក្នុងការរៀបចំវេទិកាសន្ទនាមតិលើវិស័យដំឡូងមីកម្ពុជា ។
- ជារួមការអនុវត្តន៍សមាសភាគដំឡូងមីដោយអង្គការ UNDP គឺមានភាពរលូន និងដំណើរការបានល្អដែលអាចនឹងឈានទៅសម្រេចលទ្ធផល, គោលបំណង, និងគោលដៅរបស់គម្រោងដូចដែលបានរំពឹងទុក។

➢ <u>សមាសភាគផលិតផលជលផលសមុទ្រ (Marine Fishery Component) អនុវត្តគម្រោងដោយ UNIDO:</u>

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការចាប់ផ្តើមអនុវត្តសមាសភាគផលិតផលជលផលសមុទ្រ នៅក្នុង ខែកញ្ញា ឆ្នាំ ២០១៤
- ធ្វើបច្ចុប្បន្នភាពផែនការអនុវត្តគម្រោងឆ្នាំ ២០១៥
- រៀបចំបង្កើតយុទ្ធសាស្ត្រទំនាក់ទំនងនិងទីផ្សារ
- កំណត់អត្តសញ្ញាណនៃភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងវិស័យផលិតផលជលផលសមុទ្រ
- ធ្វើការសិក្សាពីខ្សែចង្វាក់តម្លៃរបស់សមាសភាគផលិតផលជលផលសមុទ្រ
- ជារួមការអនុវត្តន៍សមាសភាគផលិតផលជលផលសមុទ្រដោយអង្គការ UNIDO គឺមានភាពយឺតយ៉ាវជាងការរំពឹងទុក ប៉ុន្តែទោះជាយ៉ាងនេះក្តី យើងសង្ឃឹមថាសមាសភាគនេះនឹងអនុវត្តទៅដោយរលូនបន្ទាប់ពីការសិក្សាពីខ្សែចង្វាក់តម្លៃត្រូវបានបញ្ចប់នាពេលខាងមុខ។

➢ <u>សមាសភាគសាលាបណ្តុះបណ្តាលវិជ្ជាជីវៈម្ហូបអាហារកម្ពុជា ACAC (Academy of Culinary Arts-Cambodia Component) អនុវត្តគម្រោងដោយអង្គការក្រៅរដ្ឋាភិបាល Shift360:</u>

- សមាសភាគគម្រោងនេះពុំទាន់បានដាក់ឲ្យអនុវត្តនៅឡើយ ហើយបច្ចុប្បន្ននេះគឺរង់ចាំការឯកភាពជាផ្លូវការពីក្រុមប្រឹក្សាភិបាលរបស់ EIF (EIF Board Approval)។
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម បានធ្វើការយ៉ាងជិតស្និតជា មួយអង្គការ Shift360 និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីកែលម្អឯកសាររបស់គម្រោងឲ្យស្របទៅតាមការស្នើសុំរបស់ក្រុមប្រឹក្សាភិបាល EIF ហើយបានផ្ញើជូនឯកសារទាំងនោះទៅ EIF កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៥។

- ក្រុមប្រឹក្សាភិបាលរបស់ EIF នឹងធ្វើការពិនិត្យសម្រេចលើសមាសភាគសាលាបណ្តុះបណ្តាលវិជ្ជាជីវៈម្ហូបអាហារកម្ពុជានៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៥ ខាងមុខនេះ។
- Shift360 បានឯកភាពទៅនឹងការប្រើប្រាស់ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរបាយការណ៍តាមគំរូ (Template) របស់ UNOPS ។
- SIDA និង UNOPS បានឯកភាពគ្នាក្នុងការចុះមកធ្វើបេសកកម្មត្រួតពិនិត្យរួមគ្នាទៅលើការអនុវត្តគម្រោងនេះ ។
- ក្នុងរយៈពេល ៦ ខែ ដំបូងនៃការអនុវត្តគម្រោង, SIDA នឹងបញ្ជូន Audit Team មកពិនិត្យមើលតម្រូវការចាំបាច់នានានៅក្នុងការគាំទ្រការអនុវត្តគម្រោង ។

គ. ការងារផ្នែកថវិកា:

- ថវិកានៃសមាសភាគគម្រោង High Value Silk, Milled Rice នៃកម្មវិធី CEDEP I និង Cassava, MarineFishery និង ACAC នៃកម្មវិធី CEDEP II គឺគ្រប់គ្រងប្រតិបត្តិការដោយភ្នាក់ងារអនុវត្តគម្រោងនីមួយៗលើកលែងតែសមាសភាគត្រួតពិនិត្យ និងវាយតម្លៃ គឺគ្រប់គ្រងប្រតិបត្តិការដោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលចំណាយសរុបគិតមកដល់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ មានចំនួន $68,373 ។

ឃ. ការងារផ្នែកសមាជិកក្រុមស្នូល (Core Team Members):

- សមាជិកក្រុមស្នូល (Core Team Members) ចំនួន ២៥ នាក់ (១៦ នាក់ ជាមន្ត្រីអញ្ជើញមកពីក្រសួងស្ថាប័នពាក់ព័ន្ធ និង ៩ នាក់ ទៀតជាមន្ត្រីមកពីក្រសួងពាណិជ្ជកម្ម) បាននិងកំពុងចូលរួមអនុវត្តការងារជាមួយភ្នាក់ងារអនុវត្តគម្រោង (MIE) ក្រោមកម្មវិធី CEDEP I និង CEDEP II ។
- សមាជិកក្រុមស្នូល (Core Team Members) មួយចំនួនបានចូលរួមអនុវត្តការងារយ៉ាងសកម្ម និងសហការល្អជាមួយភ្នាក់ងារអនុវត្តគម្រោងដែលបានជម្រុញនិងលើកកម្ពស់ដល់ការអនុវត្តន៍គម្រោងឲ្យទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ។
- សមាជិកក្រុមស្នូល (Core Team Members) ទាំងអស់បានទទួលការកសាងសមត្ថភាពពីកម្មវិធី EIF ជាប្រចាំតាមរយៈកម្មវិធីសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, និងដំណើរទស្សនកិច្ចសិក្សានៅក្រៅប្រទេស។

## ៣). ការសន្និដ្ឋាន និងការងារដែលត្រូវធ្វើបន្ត

- ក្រុមការងារបេសកកម្មរបស់ EIF ES និង UNOPS TFM បានជួបប្រជុំពិភាក្សាជាមួយភ្នាក់ងារអនុវត្តគម្រោង (MIEs), សមាជិកក្រុមស្នូល, ដៃគូអភិវឌ្ឍន៍, និង ផ្នែកឯកជន ដើម្បី ពិនិត្យមើលវឌ្ឍនភាពការងារ, សមិទ្ធផលសំខាន់ៗ, និងបញ្ហាប្រឈមនានា ។ ជាពិសេស ការជួបពិភាក្សាជាមួយដៃគូ

អភិវឌ្ឍស្តីពីជំនួយសម្រាប់ពាណិជ្ជកម្ម (AfT) និងការបង្កើតផែនការរយៈពេលមធ្យម (MTP) ២០១៦-២០២០។

- ក្រុមការងារបេសកកម្មរបស់ EIF ES និង UNOPS TFM បានវាយតម្លៃជារួមថា៖
  - ✓ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (DICO) មានលទ្ធភាពអនុវត្តកម្មវិធីពីរក្នុងពេលជាមួយគ្នាគឺ TDSP និង EIF ។ ការនេះបានបញ្ជាក់ច្បាស់អំពីការពង្រឹងសមត្ថភាពរបស់ DICO ក្នុងការអនុវត្តគម្រោងនានាដែលទាក់ទងនឹងជំនួយពាណិជ្ជកម្ម ។
  - ✓ DICO មានសមត្ថភាពក្នុងការសម្របសម្រួល ការធ្វើបច្ចុប្បន្នភាពនៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (CTIS 2014-2018) ។
  - ✓ សមត្ថភាព និងចំណេះដឹងរបស់ (DICO) គឺជាលទ្ធផលដ៏សំខាន់បញ្ជាក់ពីភាពជោគជ័យនៃការអនុវត្តន៍កម្មវិធី EIF Tier 1 នៅកម្ពុជា។
  - ✓ ការអនុវត្តន៍កម្មវិធីពង្រឹងសមាហរណកម្ម EIF Tier 1, និង CEDEP I នៅកម្ពុជាគឺប្រព្រឹត្តិទៅបានរលូននិងទទួលបានលទ្ធផលល្អប្រសើរ។
  - ✓ DICO ដែលជាអង្គភាពអនុវត្តគម្រោងថ្នាក់ជាតិ (NIU) គឺមានសមត្ថភាពគ្រប់គ្រាន់ រួមមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ, សមត្ថភាពលទ្ធកម្ម និងសមត្ថភាពគ្រប់គ្រង) ក្នុងការអនុវត្តន៍, ចាត់ចែង និងគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្មនៅប្រទេសកម្ពុជានាពេលខាងមុខ។
- ក្រុមការងារបេសកកម្មរបស់ EIF ES និង UNOPS TFM បានឯកភាពជាគោលការណ៍ចំពោះការស្នើសុំពន្យាការអនុវត្តកម្មវិធី EIF Tier 1 ដោយមិនមានការប្រែប្រួលទៅលើថវិកា (No-Cost Extension) រយៈពេល ៨ខែ រហូតដល់ខែ មីនា ឆ្នាំ ២០១៦។
- ក្រុមការងារបេសកកម្មរបស់ EIF ES និង UNOPS TFM ក៏បានឯកភាពជាគោលការណ៍ ចំពោះការស្នើសុំពន្យាការអនុវត្តន៍សមាសភាគ High Value Silk, Milled Rice និង M&E component របស់ CEDEP I (No-Cost Extension) រយៈពេល ៦ ខែ ដែលអាស្រ័យទៅតាមកាលបរិច្ឆេទបិទគម្រោងរបស់សមាសភាគនីមួយៗ។
- ក្រុមប្រឹក្សាភិបាលរបស់ EIF នឹងធ្វើការពិនិត្យសម្រេចលើសមាសភាគសាលាបណ្តុះបណ្តាលវិជ្ជាជីវៈម្ហូបអាហារកម្ពុជា (ACAC) នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១៥ ។
- ក្រុមការងារបេសកកម្មរបស់ EIF ES និង UNOPS TFM បានផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖
  - ✓ សមាសភាគគម្រោងរបស់ CEDEP I ដែលស្នើសុំពន្យាការអនុវត្តន៍គម្រោង ត្រូវធ្វើបច្ចុប្បន្នភាពផែនការការងារ និងផែនការថវិការបស់ខ្លួន ហើយផ្ញើជូនទៅ EIF ES និង UNOPS TFM ដើម្បីពិនិត្យ និងសម្រេចជាផ្លូវការ។

- ✓ ការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រនិរន្តរភាព (Exit Strategy) គឺជាមូលដ្ឋានគ្រឹះនៃការស្នើសុំពន្យាការអនុវត្តន៍របស់កម្មវិធី EIF Tier 1 និង CEDEP I ។ ការរៀបចំ Exit Strategy សម្រាប់កម្មវិធី EIF Tier 1 គឺចាំបាច់តម្រូវឲ្យមានការកែសម្រួលនូវរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ DICO ។
- ✓ កិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារអនុវត្តគម្រោង និង ការចូលរួមរបស់សមាជិកក្រុមស្នូល (Core Team Members) នៅក្នុងការអនុវត្តន៍ការងារគួរតែបានពង្រឹង និងលើកកម្ពស់បន្ថែមទៀត។

អាស្រ័យហេតុនេះ សូម ឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។
សូម ឯកឧត្តម **ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ឧសភា ២០១៥

**ប្រធាននាយកដ្ឋាន**

ឈឿង ពេជ្រ

ចម្លងជូន:
- ខុទ្ទកាល័យ ឯកឧត្តម ទេសរដ្ឋមន្ត្រី
- លោកជំទាវ តឹកវ៉េត កំរង
- ឯកឧត្តម អ៊ុក ប្រជា
- ឯកឧត្តម អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ
- ឯកសារ - កាលប្បវត្តិ

ស៊ីម_រ៉ា
12/05/2015

12/05/2015